**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីជូនដំណឹង
## ស្តីពីពិព័រណ៍ការងារ និងផលិតភាពជាតិអនឡាញ ឆ្នាំ២០២១
## ថ្ងៃទី៤-៥ ខែវិច្ឆិកា ឆ្នាំ២០២១

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់ក្រសួង ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារ សិស្ស-និស្សិត និងសាធារណជនមេត្តាជ្រាបថា តាមរយៈកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា (UYFC) រាជធានីភ្នំពេញ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងរៀបចំ**ពិព័រណ៍ការងារ និងផលិតភាពជាតិអនឡាញ ឆ្នាំ២០២១** (National Career and Productivity Fair 2021-Online) ដែលនឹងប្រព្រឹត្តទៅរយៈពេល ០២ថ្ងៃ ចាប់ពីថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ រហូតដល់ថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៤-៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ពិព័រណ៍ការងារអនឡាញនេះ ត្រូវបានរៀបចំក្នុងគោលបំណងផ្តល់នូវជម្រើសដែលមានភាពបត់បែនកាន់តែងាយស្រួលតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា និងដើម្បីបន្តរក្សាគុណភាពនៃដំណើរការទីផ្សារការងារ ជាពិសេសជួយជ្រោមជ្រែងដល់និយោជកដែលមានតម្រូវការជ្រើសរើសកម្លាំងពលកម្ម ព្រមទាំងបើកវេទិកាទូលាយក្នុងការទទួលបានឱកាសការងារកាន់តែងាយស្រួលដល់អ្នកស្វែងរកការងារ សំដៅចូលរួមកាត់បន្ថយហានិភ័យនៃការរីករាលដាលជំងឺកូវីដ-១៩ និងការចូលរួមអនុវត្តម៉ឺងម៉ាត់នូវវិធានការ ៣ការពារ ៣កុំ ។ ព្រឹត្តិការណ៍ការងារនេះនឹងទទួលស្វាគមន៍និយោជក និងអ្នកស្វែងរកការងារ ឱ្យចូលជ្រើសរើសកម្លាំងពលកម្ម និងដាក់ពាក្យស្នើសុំការងារតាមរយៈប្រព័ន្ធអនឡាញនៅលើគេហទំព័រ www.careerfair.nea.gov.kh ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រប់ក្រសួង ស្ថាប័ន ក្រុមហ៊ុន សហគ្រាស អង្គការជាតិ/អន្តរជាតិ អ្នកស្វែងរកការងារ និងសាធារណជន ដែលមានបំណងចូលរួមតាំងបង្ហាញ ឬត្រូវការព័ត៌មានពិស្តារអំពីពិព័រណ៍ការងារ និងផលិតភាពជាតិអនឡាញ ឆ្នាំ២០២១ សូមទំនាក់ទំនងមកទីភ្នាក់ងារជាតិមុខរបរ និងការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈទូរសព្ទលេខ ០១៧ ៨៧១ ៨០៧/០១៦ ៤៣៨ ៨៤៣។

ថ្ងៃ...... ខែ...... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ...... ឆ្នាំ២០២១